**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**មន្ទីរឧស្សាហកម្ម និងសិប្បកម្ម**
**ខេត្ត ស្ទឹងត្រែង**

**លេខៈ ................ ឧស.សត/រប**

# របាយការណ៍
# ស្តីពីលទ្ធផល និងសកម្មភាពការងារ
# ប្រចាំ ឆ្នាំ២០១៦ និងលើកទិសដៅ ឆ្នាំ២០១៧

## I.ស្ថានភាពមន្ទីរ

### ១.ការិយាល័យកិច្ចការទូទៅ

**ក.ការងារបុគ្គលិកៈ** មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តស្ទឹងត្រែង មានមន្ត្រីសរុប ទាំងអស់ចំនួន **១៦** រូប និងស្ត្រី **០៦** រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ០២ រូប ដោយក្នុងនោះមានៈ

| | |
|---|---|
| -ប្រធានមន្ទីរ | ចំនួន ០១ រូប |
| -អនុប្រធានមន្ទីរ | ចំនួន ០២ រូប |
| -ប្រធានការិយាល័យ | ចំនួន ០១ រូប |
| -ប្រធានអង្គភាព | ចំនួន ០១ រូប |
| -ប្រធានការិយាល័យក្រុង-ស្រុក | ចំនួន ០១ រូប |
| -មន្ត្រី | ចំនួន ០៩ រូប |
| -មន្ត្រីព្យួរការងារ | ចំនួន ០១ រូប |
| -មន្ត្រីជាប់កិច្ចសន្យា | ចំនួន ០២ រូប |

មន្ទីរមានការិយាល័យជំនាញថ្នាក់ខេត្តចំនួន០៤ការិយាល័យ អង្គភាពចំនួន០១អង្គភាព និងការិយាល័យថ្នាក់ក្រុង/ស្រុកចំនួន០៥ការិយាល័យ(ពុំទាន់មានមន្ត្រីទទួលបន្ទុកចំនួន០៣ស្រុក)។មន្ត្រីដែលបំពេញការងារ នៅមន្ទីរមានចំនួន **០៧** រូបបំពេញការងារ នៅអង្គភាពរដ្ឋាករទឹកចំនួន **០៦**រូប និងការិយាល័យក្រុងស្ទឹងត្រែងចំនួន**០១**រូប និងការិយាល័យស្រុក សៀមប៉ាង ០១ រូប ។

**ខ. ការងាររដ្ឋបាលៈ**

-រៀបចំឯកសារអោយមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

-លិខិតចូលនិងលិខិតចេញក្នុងឆ្នាំ២០១៦ លិខិតចូលមាន(ចំនួន៣២៥)លិខិតចេញមាន(ចំនួន១៣៥) ។

-រៀបចំឯកសារបេសកកម្មជូនប្រធានមន្ទីរនិងតាមការិយាល័យនិមួយៗចាប់ពីខែមករាដល់ខែធ្នូឆ្នាំ២០១៦។

-ស្រង់បញ្ជីវត្តមាន ចាប់ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ២០១៦ ។

-បានធ្វើរបាយការណ៏ចាប់ពី ខែមករា ដល់ ខែធ្នូជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរសេដ្ឋកិច្ច និង ហរិញ្ញវត្ថុខេត្ត។

**គ.ការផ្គត់ផ្គង់ និងហិរញ្ញវត្ថុៈ**

-បានទូទាត់ប្រេងឥន្ទនៈ និងប្រេងរំអិលឆ្នាំ ២០១៦សម្រេចបាន ១០០% ។

-បានធ្វើតារាងផ្គូរផ្គងខែ មករា ដល់ខែធ្នូ ឆ្នាំ២០១៦ជូនដល់រតនាគារខេត្តរួច។

-បានទូទាត់ប្រាក់ឧបត្ថម្ភអ្នកជំងឺឆ្នាំ ២០១៦ សម្រេចបាន ៩៩% ។

-បានធ្វើរបាយការណ៏ពីខែមករាដល់ខែ ធ្នូ ឆ្នាំ២០១៦បានជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត រួច១០០%

*១/ ការងារបៀវត្សពលកម្ម*

-បានបើកប្រាក់បៀវត្សពីខែមករា ដល់ខែធ្នូ ជូនមន្ត្រីរាជការក្នុងមន្ទីរសម្រេចបាន១០០% ។

-បានបើកបៀវត្សមន្ត្រីជាប់កិច្ចសន្យាពីខែមករា ដល់ខែ ធ្នូ ឆ្នាំ២០១៦ សម្រេចបាន១០០% ។

-បានបើកប្រាក់ឧបត្ថម្ភមន្ត្រីចូលលម្ហែមាតុភាព (គង់ សំអន) ក្នុងឆ្នាំ២០១៦ សម្រេចបាន ១០០%។

*២/ ការងារបេសកកម្ម*

-ទូទាត់សោហ៊ុយបេសកកម្មពីខែធ្នូឆ្នាំ២០១៥ដល់ខែវិច្ឆិកាឆ្នាំ២០១៦ ជូនមន្ត្រីរាជការសម្រេចបាន៨០% ។

*៣/ កាងារទូទាត់ និងរដ្ឋទេយ្យបុរេប្រទាន*

-ទូទាត់រដ្ឋទេយ្យបុរេប្រទានបាន ៦ដុំ សម្រេចបាន ១០០% ។

-ទូទាត់សម្ភារៈការិយាល័យឆ្នាំ ២០១៦ សម្រេចបាន ១០០% ។

-ទូទាត់អគ្គិសនីពីខែវិច្ឆិកាឆ្នាំ ២០១៥ ដល់ខែ វិច្ឆិកា ឆ្នាំ២០១៦ សម្រេចបាន ៩៧% ។

-ទូទាត់ថ្លៃទឹកស្អាតពីខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ខែ តុលា ឆ្នាំ២០១៦ សម្រេចបាន ៩៩% ។

-ទូទាត់សោហ៊ុយទូរស័ព្ទពីខែវិច្ឆិកា ២០១៥ ដល់ខែ តុលា ឆ្នាំ២០១៦ សម្រេចបាន៦៥,៧៨% ។

**ឃ.ការងារផ្សេងៗ**

-បានធ្វើរបាយការណ៏ខែធ្នូ ជូនក្រសួងឧស្សាហកម្ម និងសិ្បកម្ម និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត។

-បានជួសជុលពង្រឹងអាគារជំហានទី២ ឆ្នាំ២០១៦ សម្រេចបាន៩៥% ។

-ប្រជុំរៀងរាល់ចុងខែក្នុងមួយខែម្តង និងប្រជុំក្រុមការងារ ។

**២.ការិយាល័យឧស្សាហកម្ម និងសិប្បកម្ម:**

**ក.វិស័យឧស្សាហកម្មៈ**

-រោងចក្រផលិតកៅស៊ូក្រៃបរបស់ក្រុមហ៊ុនសុភ័ក្រនីកា ដែលប្រើប្រាស់កំលាំងពលកម្ម៦០នាក់ក្នុងនោះមាន ស្រី៣០នាក់ ។

**ខ.វិស័យឧស្សាហកម្មតូច-មធ្យម និងសិប្បកម្មៈ**

-សហគ្រាស-សិប្បកម្មសរុបទាំងអស់ក្នុងខេត្តស្ទឹងត្រែងមានចំនួន៤៥៤មូលដ្ឋានដែលមានក្រុង០១និង ស្រុកចំនួន០៤ ដែលសហគ្រាស-សិប្បកម្មមានដូចខាងក្រោមៈ

-សហគ្រាស-សិប្បកម្មក្នុងក្រុង ស្ទឹងត្រែង មានចំនួន ១៨៦ មូលដ្ឋាន

-សហគ្រាស-សិប្បកម្មក្នុងស្រុក សៀមប៉ាង មានចំនួន ១១៨ មូលដ្ឋាន

-សហគ្រាស-សិប្បកម្មក្នុងស្រុក ថាឡាបរិវ៉ាត មានចំនួន ៧៤ មូលដ្ឋាន

-សហគ្រាស-សិប្បកម្មក្នុងស្រុក សេសាន មានចំនួន ២៤ មូលដ្ឋាន

-សហគ្រាស-សិប្បកម្មក្នុងស្រុក សៀមបូក មានចំនួន ៥២ មូលដ្ឋាន

-សហគ្រាសធុនតូច និងមធ្យមមានប្រកាសស្តីពីបង្កើតរោងចក្រ និងវិញ្ញាបនបត្រដំណើរការរោងចក្រ មានដូចខាងក្រោម៖

-ប្រកាសបង្កើតរោងចក្រពីក្រសួង មាន០២ មូលដ្ឋាន (ឆ្នាំ2016)

-ប្រកាសអនុញ្ញាតិដំណើកាពីក្រសួង ០៩ មូលដ្ឋាន

-កំពុងដាក់ពាក្យស្នើសុំប្រកាសអនុញ្ញាត្តដំណើរការពីក្រសួង មានចំនួន ០២មូលដ្ឋាន

-ប្រើប្រាស់ដើមទុនសរុបចំនួន៣.០៥៧.៣២២ដុល្លារ

-ប្រើប្រាស់កំលាំងពលកម្មសរុបចំនួន ៨២៦ នាក់ ក្នុងនោះស្រីមានចំនួន ២៧១ នាក់

-បានចុះបញ្ជីសប្បកម្មនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបានចំនួន ២៥មូលដ្ឋាន និងទទួលបានប្រកាសបង្កើតសិប្បកម្មពីក្រសួងបានចំនួន ០៣ មូលដ្ឋាន។

-បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ សហគ្រាសធុនតូច និងមធ្យម ដែលមិនទាន់មានការយល់ដឹង ចំពោះមូលដ្ឋានសិប្បកម្មមានការចុះបញ្ជីនិងស្រង់ស្ថិតិសិប្បកម្មក្នុងក្រុងស្ទឹងត្រែង បានចំនួន០៥លើកក្នុង ឆ្នាំ២០១៦នេះ។

-បានជំរុញឲ្យម្ចាស់សិប្បកម្មរៀបចំឯកសារដាក់ពាក្យស្នើសុំយកវិញ្ញាបនប័ត្រដំណើរការ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចំនួន០២ មូលដ្ឋាន។

-ការិយាល័យឧស្សាហកម្ម-សិប្បកម្ម ចាប់ពីដើមខែធ្នូ-រហូតដល់ចុងខែធ្នូ ម្ចាស់សិប្បកម្មបានមកដាក់ពាក្យសុំបន្តធ្វើសិប្បកម្ម-អាជីវកម្មក្នុងឆ្នាំ២០១៦ បានចំនួន**១៥** មូលដ្ឋាន រួចហើយ។

-បានចុះពិនិត្យនិងណែនាំដល់សហគ្រាស និងសិប្បកម្មឲ្យធ្វើការសំអាតអនាម័យនៅតាមទីធ្លាសហគ្រាស និងសិប្បកម្ម បានចំនួន០៤លើក ។

-បានអញ្ជើញម្ចាស់សហគ្រាសមកធ្វើការណែនាំបានចំនួន ០៥សហគ្រាស ស្តីពីការគ្រប់គ្រង់រោងចក្រ-សហគ្រាសធុនតូច និងមធ្យម ។

-បានចុះធ្វើការត្រួតពិនិត្យលើបច្ចេកទេសផលិតស្រាស និងបានធ្វើកំណត់ហេតុ រវាងម្ចាស់សិប្បកម្មផលិត ស្រាសរអោយមកដាក់ពាក្យស្នើសុំចុះបញ្ជីសិប្បកម្មនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត ឲ្យបានទាន់ពេលវេលាតាម ការកំណត់។

-បានជំរុញឲ្យម្ចាស់សិប្បកម្មផលិតការ៉េមពិសារ មកធ្វើការចុះបញ្ជីសិប្បកម្មនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងបន្តយកវិញ្ញាបនប័ត្រដំណើរការសិប្បកម្ម ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

-មន្ទីរបានធ្វើការប្រជុំជាមួយម្ចាស់អាជីវកម្ម ស្តីពីការងារពង្រឹងលើសហគ្រាសខ្នាតតូច និង មធ្យមទៅលើបញ្ហាការផលិត និងគុណភាពផលិតផល ក្បួនខ្នាតអនាម័យស្អាត(ស៥) និការវិចខ្ចប់ផលិតផល ។

-បានណែនាំដល់ម្ចាស់សិប្បកម្មមានបំណងចង់បង្កើតសិប្បកម្មទឹកពិសាដប(អង្គក្លាសិត)និងមូលដ្ឋាន សិប្បកម្មទឹកពិសាដប(អង្គមាស) ដើម្បីស្នើសុំយកវិញ្ញាបនប័ត្រដំណើរការសិប្បកម្មពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

-បានជំរុញម្ចាស់អាជីវករផលិតទឹកកកដើម ឲ្យមកដាក់ពាក្យស្នើសុំចុះបញ្ជីនូវក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទីតាំងស្ថិតក្នុង ភូមិ ព្រះរំកិល ឃុំ ព្រះរំកិល ស្រុក ថាឡាបរីវ៉ាត ខេត្ត ស្ទឹងត្រែង។

**៣.ការិយាល័យទឹកស្អាត**

-បានធ្វើការជំរុញដល់ម្ចាស់អាជីវកម្មចែកចាយទឹកស្អាតរបស់លោក **វ៉ន ប្រុស** ក្នុងស្រុកសៀម ប៉ាង និងធ្វើការណែនាំឲ្យម្ចាស់អាជីវកម្មយកប្រកាសអនុញ្ញាត្តពីក្រសួងឧស្សាហកម្ម និងសិប្ប កម្ម(កំពុងរងចាំប្លង់អាជីវកម្ម)

**៤.ការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ:**

ក.ការងារស្តង់ដារ:

**-បានចុះធ្វើការពិនិត្យការងារស្តង់ដារនៅតាមរោងចក្រសហគ្រាស និងសិប្បកម្មរួមមានរោងចក្រទឹកកកដើមចំនួន០៣កន្លែង ,ទឹកកកអនាម័យចំនួន០៣កន្លែង ,ទឹកពិសារដបចំនួន០៤កន្លែងបានណែនាំឲ្យម្ចាស់រោងចក្រសហគ្រាស និងសិប្បកម្ម រៀបចំឲ្យមានអនាម័យល្អទៅតាមបច្ចេកទេសស្តង់ដារ បានចំនួន ពីរលើក ។**

**-ចុះធ្វើការផ្សព្វផ្សាយច្បាប់ស្តង់ដារនៅតាមរោងចក្រសហគ្រាសនិងសិប្បកម្មបានចំនួន០២លើក ដើម្បីឲ្យម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មអនុវត្តច្បាប់ស្តង់ដារ ដើម្បីឲ្យមានគុណភាព ។**

**-ចូលរួមកម្មវិធីបណ្តុះបណ្តាលអំពីអធិការកិច្ចផ្នែកម្ហូបអាហារចំនួន៥ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែវិច្ឆកា ឆ្នាំ ២០១៦ នៅវិទ្យាស្ថានស្តង់ដារកម្ពុជា (ភ្នំពេញ) ។**

ខ.ការងារមាត្រាសាស្ត្រ:

-បានជូនដំណឹងដល់ម្ចាស់ស្ថានីយ៍ប្រេង និងម្ចាស់ដេប៉ូលក់ចែកចាយប្រេងឥន្ធនៈស្តីពីការចុះបញ្ជីមាត្រាសាស្ត្រក្នុងឆ្នាំ២០១៦យោងប្រកាស់លេខ១៧៩ MIH/2014 ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ២០១៤ ស្តីពីនិតិវិធីនិងបែបបទនៃការស្នើសុំចុះបញ្ជីមាត្រាសាស្ត្រកម្ពុជា ជូនដល់ម្ចាស់ស្ថានីយ៍ប្រេង និងម្ចាស់ដេប៉ូលក់ចែកចាយប្រេងឥន្ធនៈចំនួន០២ លើក ។

នៅក្នុងខេត្តស្ទឹងត្រែងមានស្ថានីប្រេងនិងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈ សរុប មានចំនួន៣០កន្លែងរួមមាន ៖

-ស្ថានីយ៍ និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈសូគីម៉ិចមានចំនួន ១១ កន្លែង

-ស្ថានីយ៍ និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈតេលា មានចំនួន ១២ កន្លែង

-ស្ថានីយ៍ និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈL.H.R មានចំនួន ០៧ កន្លែង

-ទូរបែងចែកប្រេងសរុប មានចំនួន ៧០ ទូរ

-ដៃបាញ់ប្រេងសរុបមានចំនួន២៥៨ ដៃបាញ់

-ដៃបាញ់ប្រេងបានប្រើមានចំនួន១០០ ដៃបាញ់

-ដៃបាញ់ប្រេងមិនបានប្រើមានចំនួន៦៤ ដៃបាញ់

-ដៃបាញ់ប្រេងខូច មានចំនួន៦៨ ដៃបាញ់

-ស្ថានីយ៍ក្រុមហ៊ុនL.H.R ចំនួន០៤កន្លែង ដៃបាញ់ប្រេងមានចំនួន២៦ដៃ ពុំបានចូលរួមនិងសហការណ៏ជាមួយជុំនាញ ។

-ចុះធ្វើការត្រួតពិនិត្យលើ ឧបករណ៏បែងចែកដៃបាញ់ប្រេងនៅតាមស្ថានីយ៍ប្រេង និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈ បានចំនួន៤ លើកដែលមាននៅក្នុងក្រុងនិងនៅតាមបណ្តាស្រុកក្នុងខេត្តស្ទឹងត្រែងដើម្បីរកកម្រិតលំអៀងបច្ចេកទេស (+ -1 %) បូកដកមួយភាគរយ តាមកម្រិតលំអៀងអនុញ្ញាត្ត បានត្រឹមត្រូវបានចំនួន៧០ភាគរយ ។

-ចូលរួមវគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពី ការត្រួតពិនិត្យទំនិញវេចខ្ចប់ ចំនួន ០៥ថ្ងៃ ចាប់ពីថ្ងៃទី០៥ ដល់ ថ្ងៃទី ដល់ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ នៅសណ្ឋាគារ Samnang Laor phnom ( រាជធានីភ្នំពេញ ) ។

**គ.អំពីផ្នែកជញ្ជីង**

**-ចុះស្រង់ទិន្នន័យស្ថិតិជញ្ជីងតោននៅក្នុងក្រុង និងនៅតាមបណ្តាស្រុកក្នុង ខេត្តស្ទឹងត្រែងំ មានចំនួន ០២លើក**

សរុបជញ្ជីងតោនមានចំនួន ០៨ គ្រឿង រួមមានជញ្ជីងថ្លឹងដំឡូងមីចំនួន ០៧គ្រឿង ក្នុងនោះមានជញ្ជីងទម្ងន់៨០ តោនមានចំនួន០១ គ្រឿង ជញ្ជីងទម្ងន់៣០តោនមានចំនួន០១គ្រឿង ជញ្ជីងទម្ងន់២០តោនមានចំនួន០៤គ្រឿង ជញ្ជីង០៥ តោនមានចំនួន០១គ្រឿងនិងជញ្ជីងថ្លឹងផ្លូវរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្តស្ទឹងត្រែងមានចំនួន០១គ្រឿង។

-បានចុះធ្វើការស្រង់ស្ថិតិទិន្នន័យការប្រើប្រាស់ជញ្ជីងមិនស្វ័យប្រវត្តិដែលមានសមត្ថភាពក្រោ ១០០០ គីឡូចុះក្រោមនៅតាមបណ្តាឃុំព្រះបាទបានចំនួន ៥៣ ជញ្ជីង ។

-ចុះទៅកាត់ឯកសណ្ឋានមន្ត្រីមាត្រាសាស្ត្រនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ភ្នំពេញ ០១លើក ។

-ទៅចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារមាត្រាសាស្ត្រ ឆមាសទី១ ឆ្នាំ២០១៦ បញ្ហាប្រឈម និងទិសដៅអនុវត្តន៍បន្ត នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ភ្នំពេញ ០១លើក ។

**៥.អង្គភាពរដ្ឋាករទឹក:**

អង្គភាពរដ្ឋាករទឹកស្ទឹងត្រែងមានបុគ្គលិកកម្មករសរុបទាំងអស់ចំនួន២១នាក់ ក្នុងនោះមានៈ

-ក្របខ័ណ្ឌរដ្ឋចំនួន ០៦នាក់ ស្រី ០២នាក់

-មន្ត្រីជាប់កិច្ចសន្យាចំនួន ១៥នាក់ប្រុស ក្នុងនោះស្រី ០២នាក់

ក.<u>ការងារបណ្តុះបណ្តាល-កិច្ចប្រជុំ</u>

-នៅថ្ងៃទី២៥,២៦និង២៧ ខែ មករា ឆ្នាំ២០១៦ លោកស្រី ប្រធានអង្គភាព និងមន្ត្រីទទួលការងារផែនការ ទៅចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយឯកសារគតិយុត្តដល់ប្រតិបត្តិករទឹកស្អាតឯកជន និងសាធារណៈទូទាំង ប្រទេស។ និងធុរៈកិច្ចវិស័យទឹកស្អាតកម្ពុជា-ជប៉ុន នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

-នៅថ្ងៃទី១-២-៣ ខែ កុម្ភៈ ឆ្នាំ២០១៦ លោកស្រីប្រធានអង្គភាព និងមន្ត្រីទទួលការងារផែនការ ទៅចូលរួម សន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ២០១៥ និងទិសដៅការងារសម្រាប់អនុវត្ត ឆ្នាំ ២០១៦។

-នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ អង្គភាពធ្វើបទបង្ហាញស្តីពីរបាយការណ៍លទ្ធផលផលិតកម្មអាជីវកម្ម ឆ្នាំ ២០១៥ជូនគណប្រតិភូក្រសួងចុះបេសកកម្មត្រួតពិនិត្យពីវឌ្ឍនភាពរបស់អង្គភាពរដ្ឋាករទឹកខេត្តស្ទឹងត្រែង។

-នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ លោកស្រីប្រធានអង្គភាព ទៅចូលរួមសិក្ខាសាលាស្តីពី ការសិក្សាបុរេសមិទ្ធិសិក្សាគម្រោង និងការរៀបចំប្លង់វិស្វកម្មបឋមសម្រាប់ប្រព័ន្ធទឹកស្អាត និងទឹកស្អុយជាមួយធនាគារអភិវឌ្ឍន៍អាស៊ី នៅសណ្ឋាគារអ៊ឹមភើរៀលហ្គាឌិននិងវិឡា។

-នៅថ្ងៃទី២៦ខែឧសភាឆ្នាំ២០១៦ លោកស្រីប្រធានអង្គភាព និងមន្ត្រីទទួលបន្ទុកផែនការទៅចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពវិស័យទឹកស្អាតទីប្រជុំជនទូទាំងប្រទេស នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

-ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៦ លោកស្រីប្រធានអង្គភាព និងមន្ត្រីទទួលបន្ទុកការងារ គណនេយ្យ០១រូប ទៅចូលរួមសិក្ខាសាលា ស្តីពីការរៀបចំផែនការអាជីវកម្មរយៈពេលវែងនៅក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

-ថ្ងៃទី២៥-២៩ ខែកក្កដា ឆ្នាំ២០១៦ មន្ត្រី បុគ្គលិកអង្គភាពរដ្ឋាករទឹក០២រូបទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្លាស់ប្តូរនាឡិកាតំបន់ ដើម្បីកាត់បន្ថយទឹកបាត់បង់ នៅខេត្តស្វាយរៀង។

-ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកស្រីប្រធានអង្គភាពរដ្ឋាករទឹក និងមន្ត្រីជំនាញ០១រូប បានទៅចូលរួមពិភាក្សាស្តីពី ការរៀបចំកសាងផែនការផលិតកម្ម អាជីវកម្ម ឆ្នាំ២០១៧ នៅក្រសួងឧស្សា ហកម្ម និងសិប្បកម្ម។

-ថ្ងៃទី៥ ដល់ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ អង្គភាពរដ្ឋាករទឹក បញ្ជូនមន្ត្រី បុគ្គលិក ផ្នែកបណ្តាញ ចំនួន០២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកាត់បន្ថយទឹកបាត់បង់ នៅរដ្ឋាករទឹកខេត្តកំពង់ចាម។

**ខ- ការងាររដ្ឋបាលទូទៅ**

-បានធ្វើសំណើសុំដីមាត់ទន្លេមួយកន្លែង សម្រាប់សាងសង់ស្ថានីយ៍បូមទឹកល្អក់ដែលស្ថិតនៅ ភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

-ចាប់ពីថ្ងៃទី៩ ដល់ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ក្រុមការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចុះមកអធិការកិច្ចផ្នែកគណនេយ្យ និងជួយសម្រួលការងារមួយចំនួនបានរួចរាល់ជាស្ថាពរ។

-អង្គភាពបានចូលរួមយុទ្ធនាការផ្តល់ទឹកស្អាត ចែកជូនប្រជាពលរដ្ឋក្នុងភូមិ ដែលខ្វះខាតទឹកស្អាតប្រើប្រាស់ ចំនួន4ភូមិ ក្នុងស្រុកថាឡាបរិវ៉ាត់ ចំនួន12រថយន្ត ស្មើនឹង60 ម៉ែត្រគ្រីគុណ គិតជាទឹកប្រាក់90,000រៀល។

-ផ្តល់ទឹកស្អាតជូនរថយន្តអគ្គីភ័យចំនួន ៤២រថយន្តស្មើនឹង២១០ម$^{៣}$ គិតជាទឹកប្រាក់ចំនួន315,000រៀល

-ផ្តល់ទឹកស្អាតជូនសាលាខេត្តចំនួន៨ឡាន ស្មើនឹង ៤០ម$^{៣}$ គិតជាទឹកប្រាក់ចំនួន 60,000រៀល។

-ផ្តល់ទឹកស្អាតជូនមន្ទីរបក្សខេត្តចំនួន ៣ឡាន ស្មើនឹង ១៥ម$^{៣}$ គិតជាទឹកប្រាក់ចំនួន 22,500 រៀល។

-ផ្តល់ទឹកជូនរថយន្តអគ្គីភ័យពន្លត់ភ្លើងឆេះផ្សារចំនួន ២៣០ឡាន ស្មើនឹង១១៥០ម$^{៣}$ គិតជាទឹកប្រាក់ចំនួន 1,725,000រៀល។

-ផ្តល់ទឹកជូនរថយន្តអគីភ័យពន្លត់ភ្លើងឆេះព្រៃចំនួន០៦ឡានស្មើនឹង៣០ម$^{៣}$គិតជាទឹកប្រាក់45,000រៀល

-ផ្តល់ទឹកជូនរថយន្តអគីភ័យពន្លត់ភ្លើងឆេះផ្ទះចំនួន០៣ឡានស្មើនឹង១៥ម$^{៣}$គិតជាទឹកប្រាក់22,500រៀល

-ផ្តល់ទឹកជូនសាលានគរបាលជាតិភូមិភាគ១ចំនួន 17រថយន្ត ស្មើនឹង 85ម៉ែត្រគ្រីគុណ គិតជា ទឹកប្រាក់ 127,500 រៀល។

-បរិមាណទឹកផ្គត់ផ្គង់ដែលមិនផ្តល់ចំណូលសរុបឆមាសទី១ឆ្នាំ២០១៦ ចំនួន1,605ម$^{៣}$ គិតជាទឹកប្រាក់ចំនួន 2,407,500 រៀល។

**គ-ការងារផលិតកម្ម**

-បានធ្វើផែបណ្តែតលើទឹកដែលមានទំហំ ៤មX ៤ម ដំបូលប្រក់សង្ក័សីរួចរាល់។

-បរិមាណផលិត និងប្រើប្រាស់វត្ថុធាតុដើម

-បរិមាណទឹកផលិត =861,153 ម៉ែត្រគ្រីគុណ

-បរិមាណទឹកលក់ =676,794 ម៉ែត្រគ្រីគុណ

-បរិមាណទឹកបាត់បង់ =184,359 ម៉ែត្រគ្រីគុណ

| បរិយាយ | ម្សៅPAC | ក្លរ | ថាមពលអ/នី | ប្រេងម៉ាស៊ូត | ប្រេងម៉ាស៊ីន | ប្រេងសាំង | ខ្លាញ់គោ |
|---|---|---|---|---|---|---|---|
| **ចំនួន** | 37,597kg | 5,132kg | 382,477Kw/h | 0 L | 00 | 0 L | 24kg |

- **ជួសជុល និងថែទាំរោងចក្រ**

-លាងអាងប្រោះ =366ដង

-លាងអាងកូរសាច់ដូរ =36 ដង

-លាងអាងរងបាន =36 ដង

-លាងអាងកូរPac = 12 ដង

-លាងអាងស្តុក = 1 ដង

**ឃ-ការងារបណ្តាញ**

-ការកាត់បន្ថយទឹកបាត់បង់

-ចុះស្រាវជ្រាវទឹកលេចធ្លាយដោយប្រើប្រាស់ឧបករណ៍Listening bar និងធ្វើការជួសជុលបានទាន់ពេលវេលា។

-ជួសជុល និងថែទាំបណ្តាញមេ និងបណ្តាញចែកចាយ

-សរុបប្រវែងបណ្តាញដែលមានចំនួន 31,599ម៉ែត្រ

-បានស្រាវជ្រាវរកឃើញទឹកលេចធ្លាយ និងធ្វើការជួសជុលឡើងវិញបានចំនួន 899កន្លែង អស់ទុយោប្រវែង 3,947 ម៉ែត្រ ដូចបានរាយលំអិតក្នុងតារាងខាងក្រោម:

| ប្រភេទ¢ | 200 | 150 | 100 | 90 | 80 | 60 | 49 | 42 | 34 | 27 | 21 | សរុបក្នុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនកន្លែង | 11 | 0 | 68 | 2 | 34 | 165 | 110 | 14 | 34 | 176 | 285 | 899កន្លែង |
| ចំនួនម៉ែត្រ | 35 | 0 | 225 | 4 | 205 | 1072 | 608 | 60 | 148 | 666 | 898 | 3,947ម៉ែត្រ |

**ង-ការងារអាជីវកម្ម**

-បានអនុវត្តលើការអាននាឡិការៀងរាល់ថ្ងៃ។

- **ការងារតបណ្តាញចូលផ្ទះ**

-តបណ្តាញចូលផ្ទះ បានចំនួន១៧គ្រួសារ

- **ការងារទំនាក់ទំនងអតិថិជន**

-ចំនួនអតិថិជនសរុបដើមគ្រា ២,៥១៨ អតិថិជន

-កំណើនក្នុងគ្រា ១៧ អតិថិជន

-ចំនួនអតិថិជនសរុបចុងគ្រា ២,៥៣៥ អតិថិជន

**-ដំណោះស្រាយភាពមិនប្រក្រតីក្នុងការប្រើប្រាស់ទឹក**

| | អធិប្បាយពន្យល់ | សំណល់ដើមឆ្នាំ | សរុបពីដើមឆ្នាំដល់ចុងឆ្នាំ | ដោះស្រាយរួចសរុប | មិនទាន់ដោះស្រាយសរុប |
|---|---|---|---|---|---|
| ១ | កាត់ទឹក | | 90 | 90 | |
| ២ | ប្តូរនាឡិកាខូច(គាំង) | | 154 | 154 | |
| ៣ | ប្តូរទីតាំងនាឡិកា | | 164 | 164 | |
| ៤ | ខូចវ៉ានជម្មតា | | 320 | 320 | |
| ៥ | ដោះលាង និងប្តូរបេ | | 308 | 308 | |

## II.ការដឹកនាំចូលរួមប្រជុំនានារបស់ប្រធានមន្ទីរ

-លោកប្រធានមន្ទីរបានចូលរួម ប្រជុំសាមញ្ញលើកទី ១៩អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត

-លោកប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំពិនិត្យពិគ្រោះយោបល់លើសំណើរ សុំតែងតាំងមន្ត្រីរាជការរបស់មន្ទីរអង្គភាពសាមី ។

-លោកប្រធានមន្ទីរបានចុះបេសកកម្មស្តីពីការងារមាត្រាសាស្ត្រនិងបញ្ហាប្រឈម ។

-លោកប្រធានមន្ទីរបានចុះបេសកកម្ម ចូលរួមសិក្ខាសាលាស្តីពី"ធុរៈកិច្ចវិស័យទឹកស្អាតកម្ពុជា-ជប៉ុន" ។

-លោកប្រធានមន្ទីរបានចុះបេសកកម្មចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ឆ្នាំ២០១៥ និងទិសដៅអនុវត្តការងារ ឆ្នាំ២០១៦ ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំសាមញ្ញលើក ទី២០អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត ។

- លោកប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំគណ: អភិបាលខេត្ត និងមន្ទីរអង្គភាព ជុំវិញខេត្តប្រចាំឆ្នាំ២០១៦។

- លោកប្រធានមន្ទីរបានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធី បើកការប្រកួតកីឡាមហាជន ជ្រើសរើសជើង**ឯក**ថ្នាក់ ខេត្ត ប្រចាំឆ្នាំ២០១៥ ។

- លោកប្រធានមន្ទីរបានចូលរួមកិច្ចប្រជុំពិភាក្សាលើការឧបត្ថមថវិកា សំរាប់ក្រុមសិល្ប:ដែលត្រូវទៅចូលរួមការប្រឡងនៅសាលមហោស្រពនៅរាជធានីភ្នំពេញ ។

- លោកប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំ អនុ គណ:កម្មាការសុវត្ថិភាពចរាចរណ៏ផ្លូវគោក ។

-លោកប្រធានមន្ទីរបានចូលរួមក្នុងពិធីចែកអំណោយជូនប្រជាពលរដ្ឋក្រីក្ររងគ្រោះដោយធម្មជាតិ ឆ្នាំ២០១៥

-លោកប្រធានមន្ទីរបានអមដំណើរ **ឯកឧត្តមអភិបាល នៃគណ:អភិបាលខេត្ត** ចុះទៅសម្ពោធឧបដ្ឋាន សាលានៅវត្តគាមុនីវន្ត ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំផ្ទេរភារកិច្ចថ្នាក់អគ្គនាយក ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំត្រៀមរៀបចំក្នុងពិធីអបអរសាទទិវាអន្តរជាតិនារី៨មីនាខួបលើកទី១០៥ ឆ្នាំ២០១៦ លើប្រធានបទ(វិនិយោសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍប្រដោយចីរភាព) ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំផ្សព្វផ្សាយលទ្ធផលសន្និបាតបូកសរុបការប្រចាំឆ្នាំ២០១៥ និងទិសដៅការរបស់ក្រសួងមហាផ្ទៃ ។

-លោកប្រធានមន្ទីរបានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទទិវាអន្តរជាតិនារី៨មីនាខួបលើកទី១០៥ ឆ្នាំ២០១៦ លើប្រធានបទ(វិនិយោសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍប្រដោយចីរភាព) ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំឆ្លងរបាយរណ៏ប្រចាំខែកុម្ភ:ឆ្នាំ២០១៦ ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំសាមញ្ញលើកទី២១ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត ។

-លោកប្រធានមន្ទីរបានចុះបេសកកម្ម ចូលរួមកិច្ចប្រជុំ**ស្តីពីការធ្វើផែនការក្រប ខណ្ឌសម្រាប់ឆ្នាំ២០១៧**(សាលបណ្តុះបណ្តាល) ។

-លោកប្រធានមន្ទីរបានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបិទការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ ខេត្តប្រចាំឆ្នាំ២០១៦ ។

- លោកប្រធានមន្ទីរបានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០១៥ និងទិសដៅការបន្តឆ្នាំ២០១៦ របស់សមាគមន៏ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តស្ទឹងត្រែង ។

- លោកប្រធានមន្ទីរបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី កម្មវិធីផែនការ សុវត្ថិភាពទឹក ។

-លោកប្រធានមន្ទីរបានចូលរួមក្នុងកម្មវិធីសូត្រមន្តអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរជា មួយថ្នាក់ដឹកនាំខេត្ត នៅវត្តពោធិញាណ ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំឆ្លងរបាយរណ៍ប្រចាំខែមីនាប្រចាំ ត្រីមាសទី១ និងផែនការ សកម្មភាព សំខាន់ៗក្នុងខេត្ត ។

-លោកប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំស្តីពីពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ។

-លោកប្រធានមន្ទីរបានចូលរួមប្រជុំសាមញ្ញ លើកទី ២២ អាណត្តិ ទី ២ របស់ ក្រុម ប្រឹក្សា ខេត្ត ។

-លោកប្រធានមន្ទីរបានចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យការទប់ស្កាត់ និងដោះស្រាយបញ្ហា ទំនាស់ ដីធ្លីក្នុង ខេត្តស្ទឹងត្រែង ។

-លោកប្រធានមន្ទីរបានចុះបេសកកម្ម **ចូលរួមពិធីសម្ពោធរោងចក្រ ស្ករស ក្រុមហ៊ុន** RUIFENG ( CAMBDIA ) INTERNATIONALCOMPANYLIMITED ) នៅ**ក្រុមហ៊ុន រួយហ្វេង ស្រុកឆែប**ខេត្តព្រះ វិហារ ។

- លោកប្រធានមន្ទីរបានចូលរួមប្រជុំស្តីពីការត្រួតពិនិត្យកាទប់ស្កាត់និងដោះស្រាយទំនាស់ ដីធ្លីក្នុងខេត្ត ។

-លោកប្រធានមន្ទីរបានចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រកាសសម្ពោធដាក់ដំណើរការប្រពន្ធ័ផលិតកម្មនិងចែកចាយទឹកស្អាតខេត្តមណ្ឌលគិរី ។

-លោកប្រធានមន្ទីរបានក្នុង**ពិធីបំពាក់**ឯក**សណ្ឋានមន្ត្រីនគបាលយុត្តិធម៌នៅមជ្ឈមណ្ឌលមាត្រាសាស្រ្ត ជាតិ។**

-លោកប្រធានមន្ទីរបានក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារសាលប្រជុំវរៈសេនាតូចការពារ ព្រំដែនជើងគោកលេខ ៧០១ខេត្ត ។

-លោកប្រធានមន្ទីរ និងប្រធានការិកិច្ចការទូទៅបានចុះបេសកកម្មវគ្គបណ្តុះបណ្តាល អំពីវិធាននិងបទប្បញ្ញាត្តិស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១៧ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ក/១ ការចូលរួមប្រជុំនានារបស់អនុប្រធានមន្ទីរ**

- លោកអនុប្រធានមន្ទីរបានក្នុងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ នៅសាលាខេត្ត ។

-លោកអនុប្រធានមន្ទីរបានក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តក្រុងស្រុកឃុំសង្កាត់ ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្ត ចតុកោណដំណាក់កាលទី៣ នៅសាលាខេត្ត ។ -លោកអនុប្រធានមន្ទីរបានក្នុងកិច្ចប្រជុំក្រុមការងារចុះស្រង់ស្ថិតិផលប៉ះពាល់បង្ករដោយអគ្គីភ័យ និងរៀបចំ កន្លែងលក់ដូរបណោះអាសន្នសារជាថ្មីឡើងវិញជូនអាជីវករ ។

-លោកអនុប្រធានមន្ទីរបាន ក្នុងកិច្ចប្រជុំអនុណៈកម្មការចុះស្រង់ស្ថិតិលំនៅដ្ឋានគ្រឹះស្ថានសាធារណៈសណ្ឋាគារផ្ទះសំណាក់ផ្ទះជួលភោជនីដ្ឋានទីតាំងអាជីវករដើម្បីរៀបចំអនាមយ័បរិស្ថាននិងសំរាមសំណល់រឹងក្នុងក្រុងស្ទឹងត្រែង។

-លោកអនុប្រធានមន្ទីរបានចូលក្នុងកម្មវិធីសូត្រមន្តបង្សុកូលជូនអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាមនិងជំនួយការវៀតណាមដែលបានពលីនៅកម្ពុជា ធ្វើមាតុភូមិនិវត្តន៏។

- លោកអនុប្រធានមន្ទីរ បាន**ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ**ដំណើរការសមាហរណកម្មផែនការថ្នាក់ក្រុងស្រុក។

-លោកអនុប្រធានមន្ទីរបានចូលរួមស្តីពីការរៀបចំសិក្ខាសាលាសមាហរណកម្មផែនការសង្កាត់នៅថ្នាក់ក្រុង។

-លោកអនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាសមាហរណកម្មផែនការឃុំ/សង្កាត់នៅថ្នាក់ស្រុក ( សេសាន )។

-លោកអនុប្រធានមន្ទីរបានចូលរួមសិក្ខាសាលាសមាហរណកម្មផែនការឃុំ/សង្កាត់នៅថ្នាក់ស្រុកថាឡាបរីវ៉ាត់។

-លោកអនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការផ្សព្វផ្សាយលទ្ធផលទិន្នន័យគ្រួសារ ក្រីក្រ ឆ្នាំ ២០១៦។

-លោកអនុប្រធានមន្ទីរបានចូលរួមក្នុងកម្មវិធីសម្ពោធប្រព័ន្ធចែកចាយទឹកសហគមន៍ជូនប្រជាពលរដ្ឋភូមិ កំភុន ឃុំកំភុន ស្រុកសេសាន ។

-លោកអនុប្រធានមន្ទីរបានចូលរួមជាភ្ញៀវកិត្តិយស សិក្ខាសាលាសមាហរណកម្ម ផែនការ កម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក(២០១៦-២០១៨)និងកម្មវិធីវិនិយោគឃុំ ឆ្នាំ២០១៧ ។

-លោកអនុប្រធានមន្ទី បានចូលរួមប្រជុំបូកសរុបប្រចាំឆ្នាំនិងលើកទិសដៅការងារបន្តសម្រាប់ក្រុមការងារដើម្បីកុមារ និងអនុក្រុមការងារដើម្បីកុមារមន្ទីរឧស្សាហកម្ម និងសិប្បកម្ម (នៅខេត្ត សៀមរាប)។

-លោកអនុប្រធានមន្ទីរបានប្រជុំក្រុមការងារកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

-លោកអនុប្រធានមន្ទីរ បានចូលរួមកិច្ចប្រជុំក្រុមការងារខេត្តចុះមូលដ្ឋានក្រុង ស្រុក និងឃុំ សង្កាត់

-លោកអនុប្រធានមន្ទីរបានចូលរួមប្រជុំបូកសរុបលទ្ធផលក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្ត ក្រុង ស្រុកនិងឃុំសង្កាត់ នៃខេត្តស្ទឹងត្រែង ។

## III .បញ្ហាប្រឈម

-មានការលំបាកក្នុងការធ្វើដំណើ(ផ្លូវមួយចំនួនមានការលំបាក់)ទៅកាន់បណ្តាលស្រុកស្ថិតឆ្ងាយពីទីរួមខេត្ត ។

-ឧបករណ៏ប្រើប្រាស់ក្នុងការិយាល័យមានការខ្វះខាត់ នៅសំភារៈមួយចំនួន។

-ប្រព័ន្ធប្រព្រឹត្តកម្ម និងប្រព័ន្ធចែកចាយចាស់ទ្រុឌទ្រោម។

-មន្ទីរសោធារណការ បន្តអភិវឌ្ឍផ្លូវថ្នល់ដាក់ប្រព័ន្ធលូក្នុងក្រុង ធ្វើឲ្យប៉ះពាល់បណ្តាញទឹកជា ច្រើនកន្លែង។

-ទឹកស្អាតដែលផ្គត់ផ្គង់ជូនប្រជាពលរដ្ឋប្រើប្រាស់ មិនបានគ្រប់គ្រាន់ ជាពិសេសនៅរដូវប្រាំង

-ពុំមានឧបករណ៏សម្រាប់ធ្វើការវិភាគគុណភាពទឹក។

## IV .ទិសដៅអនុវត្តន៍បន្តសម្រាប់ឆ្នាំ២០១៧

-ចុះធ្វើការត្រួតពិនិត្យការងារស្តង់ដារនៅតាមរោងចក្រសហគ្រាសនិងសិប្បកម្មរួមមានរោងចក្រទឹកកកដើម ទឹកកកអនាម័យ , ទឹកពិសារដបបរិសុទ្ធ នៅតាមរោងចក្រ សហគ្រាស និងសិប្បកម្មដើម្បី រៀបចំកែលំអរន្ធវចំណុចខ្វះខាតកន្លងមក និងរៀបចំឲ្យមានអនាម័យល្អទៅតាមបច្ចេកទេសស្តង់ដារ ដែលបានកណត់ ។

-បន្តចុះធ្វើការផ្សព្វផ្សាយឲ្យម្ចាស់ស្ថានីយ៏ប្រេង និងដេប៉ូចែកចាយប្រេងឥន្ធនៈ មកដាក់ពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្រក្នុងឆ្នាំ២០១៧ និងម្ចាស់ស្ថានីប្រេង និងដេប៉ូចែកចាយប្រេងឥន្ធនៈ ដែលផុតសុពលភាពឲ្យមកដាក់ពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្របន្តឆ្នាំ២០១៧។

-បន្តចុះធ្វើការត្រួតពិនិត្យលើឧបករណ៏បែងចែកដៃបាញ់ប្រេងនៅតាមស្ថានីយ៏ប្រេង និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈដែលមាននៅក្នុងក្រុង និងនៅតាមបណ្តាស្រុកក្នុងខេត្តស្ទឹងត្រែង ។

-ចុះធ្វើការត្រួតពិនិត្យលើផលិតផលវេចខ្ចប់នៅតាមរោងចក្រ សហគ្រាស និងសិប្បកម្មដែលពាកព័ន្ធ ។

-ចុះធ្វើការត្រួតពិនិត្យលើជញ្ជីងមិនស្វ័យប្រវត្តន៏ ដែលមានសមត្ថភាពក្រោម ១០០០ គីឡូក្រាម ចុះក្រោម ដែលអាជីវករធ្វើអាជីវកម្មនៅតាមរោងចក្រ សហគ្រាស និងសិប្បកម្ម នៅតាមទីផ្សារទីប្រជុំជនតាមដេប៉ូទិញដំឡូងម៉ី ដែលមាននៅក្នុងក្រុង និងនៅតាមបណ្តាស្រុកក្នុងខេត្តស្ទឹងត្រែង។

-ចុះធ្វើការត្រួតពិនិត្យលើឧបករណ៏កែវក្រិតវ៉ែប្រេងដែលអាជីវករកំពុងធ្វើអាជីវកម្មនៅតាមផ្ទះ និងនៅតាមទីផ្សារ ក្នុងក្រុង និងនៅតាមបណ្តាស្រុកក្នុងខេត្តស្ទឹងត្រែង ។

-ចុះធ្វើការត្រួតពិនិត្យលើទំនិញផលិត និងទំនញវេចខ្ចប់ ដែលមាននៅតាមរោងចក្រ សហគ្រាស និងសិប្ប

កម្ម ក្នុងក្រុង និងនៅតាមបណ្ដាស្រុកក្នុងខេត្តស្ទឹងត្រែង

-ជំរុញឲ្យម្ចាស់សិប្បកម្ម និងអាជីវកម្មមកធ្វើការចុះបញ្ជីសិប្បកម្មបន្តសម្រាប់ ឆ្នាំ២០១៧ ។

-ជំរុញឲ្យម្ចាស់សិប្បកម្ម និងអាជីវកម្មមកធ្វើការចុះបញ្ជីសិប្បកម្មបន្តទៀត ក្នុងក្រុងស្ទឹងត្រែង ។

-ចុះធ្វើការណែនាំដល់មូលដ្ឋានរោងចក្រ សហគ្រាស និងសិប្បកម្មណាដែលមានលក្ខណៈខុសបច្ចេកទេស និងមានបរិស្ថានមិនល្អ ឲ្យម្ចាស់អាជីវកម្មកែលំអឡើងវិញ តាមការកំណត់របស់មន្ទីរឧស្សាហកម្ម និងសិប្ប កម្មខេត្ត បានកំណត់ជាកំហិត។

-បន្តការងារក្នុងការចុះអនុវត្តប្រមូលចំណូលជាតិ របស់មន្ទីរឧស្សាហកម្ម និងសបប្បកម្មខេត្ត ដែលបានចែងក្នុងច្បាប់បានកំណត់។

-បន្តការងារក្នុងការចុះអនុវត្តប្រមូលចំណូលជាតិ របស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត ដែលបានចែង ក្នុងច្បាប់បានកំណត់។

-បន្តធ្វើការជំរុញឲ្យម្ចាស់ស្ថានីយ៍ប្រេង និងនៅតាមដេប៉ូចែកចាយប្រេងឥន្ធនៈឲ្យមកដាក់ពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្រក្នុងឆ្នាំ២០១៧ និងម្ចាស់ស្ថានីយ៍ប្រេងនិងដេប៉ូចែកចាយប្រេងឥន្ធនៈដែលផុតសុពលភាពឲ្យមក ដាក់ស្នើសុំចុះបញ្ជីមាត្រាសាស្ត្របន្តឆ្នាំ២០១៧ ។

-បន្តជុំរុញការរុករកបណ្ដាញទឹកដែលបាក់បែក ដើម្បីធ្វើការជួសជុលឡើងវិញ។

-បន្តការងារជួសជុលបណ្ដាញទឹកលេចធ្លាយទាន់ពេលវេលា។

-បន្តការចុះស្រាវជ្រាវទឹកលេចធ្លាយដោយប្រើឧបករណ៍ Listening bar.

-បន្តការផ្លាស់ប្ដូរទីតាំងនាឡិកា ដែលមាននៅក្នុងបរិវេណរបងផ្ទះអតិថិជនឲ្យមកនៅក្រៅរបងទាំងអស់ ជៀសវាងការលួចបំបែកខុសច្បាប់។

-បន្តការងារផ្លាស់ប្ដូរនាឡិកាស្ទង់ទឹកដែលខូចនិងដោះស្រាយបញ្ហាផ្សេងៗតាមសំណូមពរ របស់អតិថិជនអោយបានទាន់ពេលវេលា។

-ខិតខំជំរុញទារបំណុលដែលអតិថិជន និង មន្ទីរអង្គភាពមួយចំនួនជំពាក់ថ្លៃប្រើប្រាស់ទឹក។

ស្ទឹងត្រែង,ថ្ងៃទី............ខែ..............ឆ្នាំ២០១៦

**អ្នកធ្វើរបាយការណ៍**

បានឃើញ និង......................

ស្ទឹងត្រែង,ថ្ងៃទី............ខែ..............ឆ្នាំ២០១៦

**ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត**